

# ប៉ុន្តែខ្ញុំនៅតែឃ្លាន

Sat Dich

Meth Phearum

Let's Read

The Asia Foundation



កូនមឹកនីណាស្រលាញ់មេវាណាស់។ វាក៏ពេញចិត្តនឹងខ្លួនឯង ដែលអាចប្រែពណ៌បានច្រើនយ៉ាង ហើយអ្វីដែលវាចូលចិត្តបំផុតនោះ គឺការញុាំ។



ថ្ងៃមួយ មុនមេវាចេញទៅរកចំណីបានផ្ដាំថា៖ «កូនត្រូវញ៉ាំចំណីនេះ ដើម្បីឆាប់ធំ ប៉ុន្តែកូនមិនត្រូវញ៉ាំអីផ្ដេសផ្ដាសនោះទេ!»



បន្ទាប់ពីមេវាចេញទៅ កូនមឹកនីណាក៏ស៊ីចំណីអស់រលីង។ ប៉ុន្តែ វានៅតែឃ្លាន កូរពោះគ្រូកៗ! ខ្លួនវាក៏ប្រែពណ៌តាមអារម្មណ៍មិនសប្បាយចិត្តរបស់វា។ «ហ៊ឹម! ចំណីនេះតិចណាស់! ខ្ញុំស៊ីមិនឆ្អែតទេ តើធ្វើម៉េចទៅ បើខ្ញុំនៅតែឃ្លានខ្លាំងយ៉ាងនេះ?»



នីណាចាំថាវាមិនត្រូវចេញទៅណាទេ ប៉ុន្តែវាពិតជាឃ្លានខ្លាំង
រំពេចនោះ វាបានលួចចេញទៅក្រៅរកចំណីស្វាត់ៗ។



កូនមឹកនីណាប្រែពណ៌ម្តងទៀតដើម្បីបញ្ឆោតកូនបង្កង ហើយចាប់ពួកវាជាចំណី។ «ឆ្ងាញ់ណាស់ ប៉ុន្តែ ខ្ញុំនៅតែឃ្លាន...»



«អេះហេ! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!» «អូ...! កូនត្រីនេះមានរសជាតិផ្អែមឆ្ងាញ់! ប៉ុន្តែ ខ្ញុំនៅតែឃ្លាន...»



«ហូ! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!» «អ្ហាក! របស់នេះ អត់ឆ្ងាញ់ទេ! ខ្ញុំនៅតែឃ្លាន!»



ពោះរបស់នីណាធំទៅៗ តែវានៅតែឃ្លាន។ «យ៉ា! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!» «យី! របស់នេះ មានរសជាតិស្រួលច្រុបៗឆ្ងាញ់ខ្លាំងណាស់! ប៉ុន្តែខ្ញុំនៅតែឃ្លាន...»



«អីយ៉ូ! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!» «អ្ហាក! របស់នេះ អត់សូវផ្អែមទេ! ប៉ុន្តែ ខ្ញុំនៅតែឃ្លាន!»



«អ៎! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!» «អាំ! របស់នេះ រឹងពិបាកលេបណាស់! ប៉ុន្តែ ខ្ញុំនៅតែឃ្លាន!»



«អុញ! តើស្អីគេនេះ? ខ្ញុំស៊ីវាសិន!...□□! ទេ! វាធំខ្លាំងណាស់។» ដោយភ័យខ្លាច កូនមឹកនីណាក៏បញ្ចេញទឹកខ្មៅដើម្បីលេបវាឱ្យបាន។ នីណាក៏សម្រេចចិត្តថា ដល់ពេលត្រឡប់ទៅផ្ទះវាវិញហើយ។



ពេលវាមកដល់ផ្ទះវិញ វាមិនអាចចូលផ្ទះបានឡើយ ព្រោះខ្លួនវាធំពេក។



«អួយៗ! ចុក...ចុកពោះខ្លាំងណាស់! ស្លាប់ឥឡូវហើយៗ!» តើនីណានឹងធ្វើយ៉ាងណាទៅ?



ចុងក្រោយ វាក៏បានសម្រេចចិត្តខ្ជាក់បង្គា បង្កង កូនត្រី ស្បោង សំបកដប ក្តាម ផ្កាថ្ម អណ្តើក និងត្រីបាឡែន ចេញវិញ ទាំងអស់។ វាក៏ប្រែរូបរាងទៅជាធម្មតាវិញ ហើយម្តាយវាក៏ត្រឡប់មកវិញដែរ។



ចាប់ពីពេលនោះមក កូនមឹកនីណាតែងតែពេញចិត្តនឹងចំណី ដែលមេវាធ្វើឱ្យ ហើយវាមិនញ៉ាំអ្វីផ្តេសផ្តាសទៀតឡើយ។





Generously supported by SMART

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ប៉ុន្តែខ្ញុំនៅតែឃ្លាន (The Greedy little Octopus)*, Author: Sat Dich. Illustrator: Meth Phearum. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/